សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ឯកសារសន្និសីទអន្តរជាតិក្រុងប៉ារីស
## ថ្ងៃ២៣ តុលា ១៩៩១ ស្តីអំពីកិច្ចព្រមព្រៀងសន្តិភាពប្រទេសកម្ពុជា ។

www.hoksavann.org

ថ្ងៃទី២២ តុលា ២០១១



កិច្ចព្រមព្រៀងស្តីអំពីដំណោះស្រាយនយោបាយរួមនៃវិវាទនៅកម្ពុជា បានចែងជាដំបូងថា រដ្ឋទាំងអស់ដែលបានចូលរួមក្នុងសន្និសីទក្រុងប៉ារីសស្តីអំពីកម្ពុជា មានចំនួន១៩ប្រទេស នៅចំពោះមុខវត្តមាននៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ដើម្បីទ្រទ្រង់ថែរក្សាព្រមទាំងការពារនូវអធិបតេយ្យ ឯករាជ្យ បូរណភាព និងភាពមិនឈ្លានពានទឹកដី អព្យាក្រិត្យ និងឯកភាពជាតិនៃកម្ពុជា ។ ដោយមានបំណងស្តាបនាឡើងវិញ ព្រមទាំងទ្រទ្រង់សន្តិភាពនៅកម្ពុជា ញ៉ាំងឲ្យមានការបង្រួបបង្រួមជាតិ និងធានាដល់ពលរដ្ឋកម្ពុជា នូវការប្រើប្រាស់សិទ្ធិរបស់ខ្លួនដោយខ្លួនឯង តាមរយៈការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ ។ ដោយជឿជាក់ថា មានតែដំណោះស្រាយរួមនៃវិវាទកម្ពុជាប៉ុណ្ណោះ ទើបត្រឹមត្រូវនិងស្ថិតស្ថេរយូរអង្វែងក្រោមការផ្តល់ជាវិភាគទានសំរាប់សន្តិភាព និងសន្តិសុខប្រចាំតំបន់ និងលើផ្ទៃរាបអន្តរជាតិបាន ។ ដោយស្វាគមន៍ចំពោះឯកសារក្របខ័ណ្ឌចុះថ្ងៃ២៨ សីហា ១៩៩០ ដោយភាគីកម្ពុជាទាំងអស់បានព្រមព្រៀងលើឯកសារទាំងមូល ចាត់ទុកជាក្របខ័ណ្ឌនៃបទបញ្ញត្តិក្នុងវិវាទនៅកម្ពុជា ដែលបន្ទាប់មកត្រូវបានយល់ព្រមជាឯកច្ឆន្ទដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ តាមសេចក្តីសំរេចចិត្តលេខ៦៤៥ ចុះថ្ងៃ១៥ តុលា ១៩៩០ ។ ដោយកត់សំគាល់ឃើញការបង្កើតនៅហ្សាការតាថ្ងៃ១០ កញ្ញា ១៩៩០ នូវឧត្តមក្រុមប្រឹក្សាជាតិកម្ពុជា ជាអង្គការស្របច្បាប់តែមួយ និងជាប្រភពនៃរដ្ឋអំណាចនៅកម្ពុជា ដែលក្នុងរយៈពេលអន្តរកាល ជានិមិត្តរូបនៃអធិបតេយ្យនិងឯកភាពជាតិ ព្រមទាំងជាតំណាងកម្ពុជានៅបរទេស ។ ដោយស្វាគមន៍ដល់ការសំរេចជាឯកច្ឆន្ទនៅប៉េកាំងថ្ងៃទី១៧ កក្កដា ១៩៩១ ក្នុងការតែងតាំងសម្តេចនរោត្តម-សីហនុជាប្រធានក្រុមប្រឹក្សាជាតិ ។ ដោយទទួលស្គាល់នូវតួនាទីដ៏ទូលំទូលាយរបស់អង្គការសហប្រជាជាតិ ដែលចាំបាច់ត្រូវបង្កើតឲ្យមានជាអាជ្ញាធរបណ្តោះអាសន្នមួយនៃអង្គការសហប្រជាជាតិនៅកម្ពុជា ដែលត្រៀមខ្លួនទាំងផ្នែកយោធា ទាំងផ្នែកស៊ីវិលបំរុងនឹងចូលធ្វើអន្តរាគមន៍ ដោយគោរពទាំងស្រុងដល់អធិបតេយ្យជាតិកម្ពុជា ។ ដោយកត់សម្គាល់នូវសេចក្តីថ្លែងការណ៍គ្រប់ការប្រជុំទាំងអស់ ជាអាទិនៅហ្សាការតា នៅថ្ងៃ៩និង១០កញ្ញា១៩៩០, នៅប៉ារីសថ្ងៃ២១និង២២ធ្នូ១៩៩០, នៅប៉ាទីយ៉ាថ្ងៃ២៤និង២៦មិថុនា១៩៩១, នៅប៉េកាំងថ្ងៃ១៦និង១៧កក្កដា១៩៩១, នៅតាបយ៉ា ថ្ងៃ២៦និង២៧សីហា១៩៩១, នៅហ្សាការតាថ្ងៃ៤និង៦មិថុនា១៩៩១ និងនៅញូវយ៉កថ្ងៃ១៩តុលា១៩៩១ ។ ដោយស្វាគមន៍សេចក្តីសំរេចចិត្តលេខ៧១៧នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនៅថ្ងៃ១៦តុលា១៩៩១ស្តីពីកម្ពុជា ។ ដោយទទួលស្គាល់នូវប្រវត្តិសាស្ត្រដែលជិតដាមដោយសោកនាដកម្មនាពេលថ្មីៗនៅកម្ពុជា ដែលកំពុងស្រែកដង្ហោយហៅរកវិធានការពិសេសដើម្បីធានា កិច្ចការពារសិទ្ធិមនុស្ស ព្រមទាំងទប់មិនឲ្យនយោបាយនិងការប្រព្រឹត្តពីមុនៗវិលត្រឡប់មកវិញបាន ។ នេះជាសេចក្តីរៀបរាប់ជាដំបូង បន្ទាប់មកទើបមានសេចក្តីព្រមព្រៀងចាត់ជាភាគជាជំពូកជាមាត្រាជាច្រើនប្រការទៀត ។

សេចក្តីប្រកាសជាដំបូងភ្ជាប់នឹងសេចក្តីយោងផ្សេងៗនេះបញ្ជាក់ថា មុននឹងមានការព្រមព្រៀងគ្នានេះ ត្រូវចំណាយពេលរាប់ឆ្នាំ ប្រជុំចុះប្រជុំឡើងរវាងភាគីខ្មែរខ្លួនឯង ដើម្បីធ្វើការសំរបសំរួលគ្នា ឆ្ពោះទៅរកឯកភាពជាតិខ្លួន ។ ចំណែកប្រទេសសហគមន៍អាស៊ីអាគ្នេយ៍, សហប្រធានទាំងពីរនៃសន្និសីទអន្តរជាតិស្តីពីកម្ពុជា បានខំប្រឹងប្រែងខ្នះខ្នែង និងឧបត្ថម្ភយ៉ាងពេញទំហឹងឆ្ពោះទៅរកដំណោះស្រាយសន្តិភាពនៅកម្ពុជា ។ ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិបានព្រមព្រៀងលើឯកសារទាំងមូល មហាសន្និបាតនៃអង្គការសហប្រជាជាតិក៏បានធ្វើសេចក្តីសំរេចចិត្តរបស់ខ្លួនចំពោះដំណោះស្រាយនេះ ។ ដូច្នេះការស្វែងរករូបមន្តដើម្បីសន្តិភាពនេះជាការពិបាកណាស់ ហើយពិបាកមួយទៀតគឺការអនុវត្តន៍ឲ្យបានត្រឹមត្រូវតាមរូបមន្តនេះ ។

តាមខ្លឹមសារនៃសន្និសីទអន្តរជាតិថ្ងៃទី២៣តុលា១៩៩១នៅទីក្រុងប៉ារីសមាន៤ចំណុច គឺត្រូវដកទ័ពបរទេសទាំងអស់ចេញពីកម្ពុជា, ត្រូវដកអាវុធពីគ្រប់ភាគីខ្មែរ, ត្រូវបោះឆ្នោតដោយសេរីនិងយុត្តិធម៌ និងកសាងកម្ពុជាឡើងវិញ ។ តើទាំង៤ចំណុចនេះត្រូវបានអនុវត្តដោយត្រឹមត្រូវឬទេ ? ។ ជាពិសេសតាមកិច្ចព្រមព្រៀង តម្រូវឲ្យការការពារអធិបតេយ្យ ឯករាជ្យ បូរណភាព និងភាពមិនឈ្លានពានទឹកដី អព្យាក្រឹត្យ និងឯកភាពជាតិនៃកម្ពុជា ត្រូវបានអនុវត្តត្រឹមត្រូវហើយឬនៅ ? រយៈកាលចំ-នួន១០ឆ្នាំដែលត្រួតត្រាដោយកងទ័ពវៀតណាម សន្ធិសញ្ញាចំនួន៤ដែលភាគីខ្មែរនិងវៀតណាមបានចុះហត្ថលេខា គឺទី១ចុះហត្ថលេខានៅថ្ងៃ១៨ កុម្ភៈ ១៩៧៩ ដើម្បីមិត្តភាពនិងសហប្រតិបត្តិការរវាងលោកហេង-សំរិន និងនាយករដ្ឋមន្ត្រីផាំ-យ៉ាំងដុងនៅភ្នំពេញ, ទី២ កិច្ចព្រមព្រៀងព្រំដែនទឹកប្រវត្តិសាស្ត្រ ចុះហត្ថលេខានៅថ្ងៃ៧ កក្កដា ១៩៨២ រវាងលោកហ៊ុន-សែននិងលោកង្វៀង-កូថាច់ រដ្ឋមន្ត្រីក្រសួងការបរទេសនៅទីក្រុងហូ-ជីមិញ, ទី៣ សន្ធិសញ្ញាលើគោលការណ៍ដំណោះស្រាយព្រំដែន ចុះហត្ថលេខានៅថ្ងៃ២០ កក្កដា ១៩៨៣ រវាងលោកហ៊ុន-សែននិងលោកង្វៀង-កូថាច់, ទី៤ សន្ធិសញ្ញាកំណត់ព្រំដែននៃជាតិទាំងពីរ ចុះហត្ថលោនៅថ្ងៃ២៧ ធ្នូ ១៩៨៥ រវាងលោកហ៊ុន-សែននិងលោកង្វៀង-កូថាច់ ។ តាមអ្នកជំនាញភូមិសាស្ត្រប្រទេសកម្ពុជានិយាយថា យោងតាមសន្ធិសញ្ញា១៩៨២ កម្ពុជាត្រូវកាត់កោះត្រល់និងកោះប្រចកសេះឲ្យទៅវៀតណាម ។ ស

ន្ធិសញ្ញាឆ្នាំ១៩៨៣ អតីតនាយករដ្ឋមន្ត្រីចាន់-ស៊ី បានចេញសរាចរថ្ងៃ៩ តុលា ១៩៨៣ បើកព្រំដែនឲ្យជនជាតិវៀតណាមចូលមករស់នៅក្នុងប្រទេសកម្ពុជាចំនួន៨ ។ តាមកិច្ចព្រមព្រៀងថ្ងៃ២៣ តុលា ១៩៩១នៅទីក្រុងប៉ារីស បានធានាការពារនូវអធិប-តេយ្យ ឯករាជ្យ បូរណភាព និងភាពមិនឈ្លានពានទឹកដី ។ ដូច្នេះតើសន្ធិសញ្ញាណាខ្លះដែលនាំឲ្យខ្មែរបាត់បង់ទឹកដី តើខ្មែរខ្លួនឯងបានចាត់ទុកសន្ធិសញ្ញាខុសច្បាប់ទាំងនោះជាមោឃភាពហើយឬនៅ ? មិនត្រឹមតែមិនចាត់ទុកជាមោឃភាពនូវសន្ធិសញ្ញាទាំងនោះទេ ថែមទាំងធ្វើសន្ធិសញ្ញាឆ្នាំ១៩៨៥ដែលមិនស្របច្បាប់ឲ្យស្របច្បាប់ថែមទៀត ។ បញ្ហាជាអាយុជីវិតជាតិនេះ ជាភារកិច្ចរបស់ជនជាតិខ្មែរគ្រប់រូបទាំងក្នុងនិងក្រៅប្រទេស ដោយនាំគ្នាដោះស្រាយជាបន្ទាន់ ដើម្បីកុំឲ្យខ្មែរបាត់បង់ទឹកដីតទៅទៀត ។

ឯកសារបញ្ជាក់ប្រវត្តិនៃកិច្ចព្រមព្រៀងសន្តិភាពនៃប្រទេសកម្ពុជាថ្ងៃ២៣ តុលា ១៩៩១នេះ មានអត្ថន័យសំខាន់ណាស់ដែលធ្វើឲ្យខ្មែរនិងខ្មែរឈប់ច្បាំងគ្នា ជានានិងគ្នា ហើយមានការធានាពីអង្គការសហប្រជាជាតិ ជាពិសេសសន្និសីទអន្តរជាតិដែលមានសមាជិក១៩ប្រទេសរួមទាំងខ្មែរផង បានចុះហត្ថលេខា បានធានាគ្រប់បែបយ៉ាង ដើម្បីឲ្យខ្មែររស់រានមានជីវិតក្នុងសន្តិភាព ក្រោយពេលដែលឆ្លងកាត់សោកនាដកម្មក្នុងចំបាំងនិងវាលពិឃាត ។ ជាពិសេស កុំឲ្យប្រទេសណាមួយចូលមកឈ្លានពានប្រទេសកម្ពុជាដូចកាលកន្លងមកហើយ។ ដូច្នេះខ្មែរគ្រប់រូបគប្បីពិចារណា គួរយកថ្ងៃ២៣ តុលា១៩៩១ ជាថ្ងៃបុណ្យជាតិ ដែលត្រូវធ្វើរៀងរាល់ឆ្នាំ ដើម្បីអបអរសាទរនូវការរួបរួមរបស់ខ្មែរ ដែលធ្វើឲ្យខ្មែររស់ឡើងវិញ និងតាំងចិត្តតទៅមុខទៀត នៅតែរួបរួមគ្នា រក្សាការពារកម្ពុជាឲ្យបានគង់វង់ជានិច្ច ។៚

*　　　　*

*